# ការរាយការណ៍ពីអំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវ

www.ibac.vic.gov.au

តើអ្នកដែលបានឃើញអំពើពុករលួយឬទេ? តើអ្នកមានការសង្ស័យលើអ្វីមួយឬទេ? ព័ត៌មានរបស់អ្នកអាចជួយ វែកបង្ហាញមុខរបៀបដែលអំពើពុករលួយក្នុងវិស័យសាធារណៈ ឬការប្រព្រឹត្តមិនត្រឹមត្រូវរបស់ ប៉ូលីសកំពុងតែធ្វើឲ្យខ្ទះខ្ទាយប្រាក់សាធារណៈ និងធ្វើឲ្យរដ្ឋវិចតូរី យ៉ារងការឈឺចាប់។ ដែលសំខាន់ នោះការប្តឹងរាយ ការណ៍របស់អ្នក អាចជួយដល់មនុស្សគ្រប់គ្នាឲ្យបានសិក្សា យល់ដឹងនូវមេរៀនដ៏មានតម្លៃនៅក្នុងការបង្ការអំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវ នាពេលអនាគត។

## តើអ្នកអាចរាយការណ៍អ្វីខ្លះទៅកាន់ IBAC?

### 1 អំពើពុករលួយដោយអង្គភាព ឬនិយោជិតវិស័យ សាធារណៈ

អំពើពុករលួយអាចជានរណាម្នាក់ដែលប្រព្រឹត្តការគែបន្លំទទួល ឬផ្តល់សំណូក សម្រេចផ្តល់នូវការចុះកិច្ចសន្យាទៅឲ្យក្រុមគ្រួសារ ឬមិត្តភ័ក្តិនិងការប្រើប្រាស់ ឬធ្វើឲ្យលេចធ្លាយនូវព័ត៌មានប្រកបដោយអភ័យឯក សិទ្ធិសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន។

អ្នកអាចប្តឹងរាយការណ៍ទៅកាន់ IBAC អំពី៖

- និយោជិតរដ្ឋាភិបាលរបស់រដ្ឋ (នៅតាមក្រសួង ភ្នាក់ងារ មន្ទីរពេទ្យរដ្ឋ សាលារៀនរដ្ឋ សាកលវិទ្យា ល័យ និងវិទ្យាស្ថាន TAFEs)
- មន្ត្រីប៉ូលីសរដ្ឋវិចតូរីយ៉ា (Victoria Police) មន្ត្រីជ្រើសរើសបុគ្គលិក មន្ត្រីសេវាកម្មការពារ (PSOs) មន្ត្រី និងនិយោជិតផ្នែកឃុំឃាំងរបស់ប៉ូលីស។
- និយោជិតសាលាក្រុង និងទីប្រឹក្សាក្រុង។
- សមាជិកសភា និងបុគ្គលិករបស់ពួកគេ
- ចៅក្រម ចៅក្រមតុលាការជាន់ទាបនិងសមាជិកតុលាការឯទៀត។

អ្នកក៏អាចជ្រើសរើសរាយការណ៍អំពីកង្វល់របស់អ្នកដោយផ្ទាល់ផងដែរ ទៅកាន់ភ្នាក់ងារដែលពាក់ព័ន្ធតាមរយៈអ្នកសម្របសម្រួលការបើកទម្លាយព័ត៌មានដោយមានការការពារ (Protected Disclosure Coordinator) របស់ស្ថាប័ននោះ។ ភ្នាក់ងារវិស័យសាធារណៈស្ទើរទាំងអស់ មាននរណាម្នាក់ដែលត្រូវបានចាត់តាំងឡើង ដើម្បីផ្តល់ជំនួយគាំពារដល់បុគ្គលិក និងសមាជិកសហគមន៍នៅ ក្នុងការប្តឹងរាយការណ៍ និងដើម្បីការពារជនវែកមុខ។

អ្នករកឃើញបញ្ជីនៃទីភ្នាក់ងារនានាដែលមានសិទ្ធិអនុញ្ញាតដើម្បីទទួលការបញ្ចេញឱ្យដឹងនៅឯ www.ibac.vic.gov.au/PID

### 2 ការប្រព្រឹត្តមិនត្រឹមត្រូវនៅក្នុងការិយាល័យ សាធារណៈ

ការប្រព្រឹត្តមិនត្រឹមត្រូវនៅក្នុងការិយាល័យសាធារណៈ ត្រូវបានគេកំណត់និយមន័យយ៉ាងធំទូលំទូលាយ។ វាអាចជាការប្រព្រឹត្តណាមួយដោយនិយោជិតវិស័យ សាធារណៈដែលមានលក្ខណៈមិនត្រឹមត្រូវតាមច្បាប់ ឬខកខានមិនបានបំពេញតាមបទដ្ឋានសីលធម៌ ឬវិជ្ជាជីវៈដែលតម្រូវឲ្យមាននៅក្នុងការបំពេញតួនាទី ឬការប្រើប្រាស់អំណាចដែលបានប្រគល់ជូនដល់ពួកគេ។

### 3 ការប្រព្រឹត្តមិនត្រឹមត្រូវដោយបុគ្គលិកប៉ូលីស រដ្ឋវិចតូរីយ៉ា (Victoria Police)

IBAC ក៏ ទទួលយកការប្តឹងរាយការណ៍ផងដែរ អំពីការប្រព្រឹត្តមិនត្រឹមត្រូវដោយបុគ្គលិកប៉ូលីសរដ្ឋវិចតូរីយ៉ា(Victoria Police) ទាំងអស់រួមមានមន្ត្រីប៉ូលីសមានអំណាចអនុវត្តច្បាប់ មន្ត្រីជ្រើសរើសបុគ្គលិក PSOs មន្ត្រីនិងបុគ្គលិកផ្នែកឃុំឃាំងរបស់ប៉ូលីស។ ការនេះអាចជាការធ្វើចែកចាយនូវសម្ភារៈដែលមានលក្ខណៈប្រមាថមើលងាយ ការបើកបរទាំងស្រវឹង ការធ្វើកំណត់ត្រាខុសនៅក្នុងបញ្ជីកំណត់ត្រា/បញ្ជីចុះកំណត់ហេតុ ឬការប្រើប្រាស់កម្លាំងជ្រុលហួសហេតុ។

ការប្តឹងរាយការណ៍ អំពីការប្រព្រឹត្តមិនត្រឹមត្រូវរបស់ ប៉ូលីស ក៏អាចធ្វើបានដែរទៅបញ្ជាការបទដ្ឋានវិជ្ជាជីវៈរបស់ប៉ូលីសរដ្ឋវិចតូរីយ៉ា(Victoria Police's Professional Standards Command) តាមទូរស័ព្ទលេខ1300 363 101.

### អ្វីដែល IBAC មិនអាចធ្វើការស៊ើបអង្កេត

- វិស័យឯកជន។
- បញ្ហាដែលកើតឡើងនៅក្នុងរដ្ឋ និងទឹកដីដទៃ ទៀត។
- សមាជិកសភាតំណាងរាស្ត្រ ក្រសួង ឬភ្នាក់ងារ រដ្ឋាភិបាលសហព័ន្ធ។

## អ្នកនឹងត្រូវបានការពារ

IBAC ដោះស្រាយព័ត៌មាន និងព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់អ្នកយ៉ាងប្រុងប្រយ័ត្ន និងស្របតាមច្បាប់ដែលពាក់ព័ន្ធ។ ប្រសិនបើបណ្តឹងតវ៉ារបស់អ្នកត្រូវបានចាត់ទុកថាជាការបញ្ចេញឱ្យដឹងពីផលប្រយោជន៍សាធារណៈ៖

- យើងនឹងមិនចែករំ លែកឈ្មោះឬព័ត៌មានលម្អិតផ្ទាល់ខ្លួនដទៃទៀតរបស់អ្នកជាមួយនរណាម្នាក់ឡើយ
- អ្នកមិនអាចគេបញ្ឈប់ពីការងារ ដាក់វិន័យ ឬត្រូវគេគំរាមកំហែងដោយសារធ្វើការប្តឹងរាយការណ៍ណាមួយឡើយ
- អ្នកត្រូវបានការពារពីការប្តឹងរាយការណ៍ ផ្លូវច្បាប់ ដូចជាការបង្ខូចកេរ្តិ៍ឈ្មោះនិងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី
- មិត្តភ័ក្តិក្រុមគ្រួសារ ឬសហសេវិករបស់អ្នកក៏ត្រូវបានការពារផងដែរ។

ប្រសិនបើបណ្តឹងតវ៉ារបស់អ្នកមិនមែនជាការបញ្ចេញឱ្យដឹងអំពីផលប្រយោជន៍សាធារណៈទេ អត្តសញ្ញាណរបស់អ្នកមិនចាំបាច់ត្រូវបានរក្សាទុកជាការសម្ងាត់ទេ ប៉ុន្តែ៖

- អ្នកមិនអាចគេបញ្ឈប់ពីការងារ ដាក់វិន័យ ឬត្រូវគេគំរាមកំហែងដោយសារធ្វើការប្តឹងរាយការណ៍ណាមួយឡើយ
- អ្នកត្រូវបានការពារពីការប្តឹងរាយការណ៍ផ្លូវច្បាប់ ដូចជាការបង្ខូចកេរ្តិ៍ឈ្មោះនិងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណ

ប្រសិនបើអ្នកមានការព្រួយបារម្ភខ្លាំងអំពីឯកជនភាពរបស់អ្នក នោះអ្នកអាចជ្រើសរើសដើម្បីធ្វើការតវ៉ាដោយអនាមិកបាន។ ប្រសិនបើអ្នកធ្វើការតវ៉ាដោយអនាមិក ការស៊ើបអង្កេតរបស់យើងនឹងត្រូវបានកម្រិតកំណត់។ ការនេះ ដោយសារតែយើងមិនអាចទាក់ទងអ្នកដើម្បីបានព័ត៌មានបន្ថែម ឬពិភាក្សាលើបណ្តឹងតវ៉ានោះ ប្រសិនបើអ្នកធ្វើបន្តទៀត។

### តើអ្វីជាការបញ្ចេញឱ្យដឹងអំពីផលប្រយោជន៍សាធារណៈ?

ការបញ្ចេញឱ្យដឹងដែលបង្ហាញអំពីការប្រព្រឹត្តិមិនត្រឹមត្រូវ ដោយមន្ត្រីសាធារណៈ ឬស្ថាប័នសាធារណៈ (ឧទាហរណ៍ អំពើពុករលួយ) ឬសកម្មភាពធ្វើឱ្យមានគ្រោះថ្នាក់ឬខូចខាត (ឧទាហរណ៍ ការបណ្តេញអ្នកណាម្នាក់ចេញពីការងារដោយសារតែបញ្ចេញព័ត៌មានឱ្យគេដឹង)។

## តើមានអ្វីកើតឡើងនៅពេលអ្នករាយការណ៍អំពីអំពើពុករលួយ និងការប្រព្រឹត្តិមិនត្រឹមត្រូវទៅ IBAC

IBAC ធ្វើការកំណត់ថាតើអ្វីដែលអ្នកបានរាយការណ៍គឺជាការបញ្ចេញឱ្យដឹងអំពីផលប្រយោជន៍សាធារណៈឬអត់

**បាទ/ចាស វាជាការបញ្ចេញឱ្យដឹងអំពីផលប្រយោជន៍សាធារណៈ។**

**ស៊ើបអង្កេត**

IBAC អាចធ្វើការស៊ើបអង្កេតបណ្តឹងតវ៉ា

**បញ្ជូនបន្ត**

IBAC អាចបញ្ជូនបន្តបណ្តឹងតវ៉ាទៅទីភ្នាក់ងារមួយនៃបណ្តាទីភ្នាក់ងារទាំងនេះដើម្បីធ្វើការស៊ើបអង្កេត៖

ទីភ្នាក់ងារ Ombudsman វិចតូរីយ៉ា ប៉ូលីសវិចតូរីយ៉ា (ប្រសិនបើជាបញ្ហាទាក់ទងនឹងប៉ូលីស) ប្រធានអធិការក្រុង ស្នងការព័ត៌មាន ស្នងការសុចរិតភាពក្នុងការប្រណាំង គណៈកម្មការគតិយុត្តិ។

ដោយមានការយល់ព្រមរបស់មនុស្សដែលបានធ្វើការតវ៉ា យើងក៏អាចបញ្ជូនបន្តបណ្តឹងតវ៉ានោះទៅស្ថាប័នសាធារណៈមួយផ្សេងទៀតដើម្បីដោះស្រាយ។

**គ្មានសកម្មភាពផ្លូវច្បាប់បន្ថែមទៀតទេ**

យើងអាចបិទ ឬបដិសេធបណ្តឹងតវ៉ាដោយសារតែហេតុផលមួយចំនួន ឧទាហរណ៍ប្រសិនបើវា៖

- ខ្វះសារធាតុជាក់ស្តែង ឬការជឿជាក់បាន
- ជាការខឹងក្តៅក្រហាយ ឬជារឿងកំប៉ិកកំប៉ុក
- ទាក់ទងនឹងរឿងក្តីដែល IBAC ឬស្ថាប័នមួយមិនបានបញ្ជាក់នៅក្នុងច្បាប់ *IBAC ឆ្នាំ 2011* អាចធ្វើការស៊ើបអង្កេតបាន។

**ទេ វាមិនមែនជាការបញ្ចេញឱ្យដឹងអំពីផលប្រយោជន៍ សាធារណៈទេ។**

**បញ្ជូនបន្ត**

IBAC អាចបញ្ជូនបន្តការបញ្ចេញឱ្យដឹងនេះទៅភ្នាក់ងារមួយទៀត (ឧ. ទីភ្នាក់ងារ Ombudsman វិចតូរីយ៉ា) ឬអង្គការដែលបានកំណត់ឈ្មោះនៅក្នុងបណ្តឹងតវ៉ា។

ការបញ្ចេញឱ្យដឹងពីការប្រព្រឹត្តិមិនត្រូវរបស់ប៉ូលីស អាចត្រូវបានបញ្ជូនបន្តទៅប្រធានស្នងការប៉ូលីស។

**គ្មានសកម្មភាពផ្លូវច្បាប់បន្ថែមទៀតទេ**

IBAC នឹងមិនចាត់វិធានការផ្លូវច្បាប់បន្ថែមទៀតទេ។

## តើអ្នករាយការណ៍ដោយរបៀបណា?

សូមបំពេញទម្រង់បែបបទប្រកបដោយសុវត្ថិភាព តាមអនឡាញនៅគេហទំព័រ www.ibac.vic.gov.au ប្រសិនបើអ្នកមានភាពលំបាកក្នុងការចូលប្រើប្រាស់ទម្រង់បែបបទតាមអនឡាន សូមទូរស័ព្ទមកយើងលេខ 1300 735 135។

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបកប្រែភាសា សូមទូរស័ព្ទទៅសេវាបកប្រែភាសាសរសេរ និងនិយាយលេខ 13 14 50 ឬ ចូលទៅកាន់វិបសាយ www.ibac.vic.gov.au/general/accessibility/tr

### មុនពេលអ្នកទាក់ទងមក IBAC

សូមឲ្យបានដឹងពីការប្ដឹងរាយការណ៍អ្វីខ្លះដែលយើងអាច និងមិនអាចទទួលយកបាន។ ប្រសិនបើការប្ដឹងរាយការណ៍របស់អ្នកមិនទាក់ទងនឹងអំពើពុករលួយ ឬការប្រព្រឹត្តមិនត្រឹមត្រូវទេ យើងអាចណែនាំអ្នកទៅកាន់ភ្នាក់ងារមួយផ្សេងទៀត ដូចជាមន្ត្រីបអង្កេតការប្ដឹងរាយការណ៍ពលរដ្ឋវិចតូរីយ៉ា(Victorian Ombudsman)។

សូមឲ្យមានភាពច្បាស់លាស់ផងដែរអំពីនរណា/អំពីអ្វីដែលអ្នកកំពុងធ្វើការប្ដឹងរាយការណ៍ និងផ្ដល់នូវ សេចក្ដីលម្អិត ឬភស្ដុតាងឲ្យបានច្រើន តាមដែលអាចធ្វើបាន។

## តើ IBAC ធ្វើអ្វីខ្លះជាមួយព័ត៌មានរបស់អ្នក?

តាមច្បាប់ IBAC នឹងចាត់អាទិភាពការចោទប្រកាន់អំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវធ្ងន់ធ្ងរ ឬជាលក្ខណៈប្រព័ន្ធ។ បន្ទាប់ពីធ្វើការវាយតម្លៃលើការប្ដឹងរាយការណ៍របស់អ្នកយ៉ាងប្រុងប្រយ័ត្នមក IBAC អាចនឹងសម្រេចចិត្ត៖

- បញ្ជូនបន្តការប្ដឹងរាយការណ៍ នោះ
- ស៊ើបអង្កេត
- មិនចាត់វិធានការតទៅទៀត។

ដើម្បីជួយយើងកំណត់អាទិភាពឲ្យត្រូវចំបញ្ហា IBAC ក៏អាចនឹងធ្វើការសាកសួរក្នុងជំហានដំបូងផងដែរ ដើម្បីគាំពារដល់សេចក្ដីសម្រេចចិត្តរបស់យើងទៅលើអ្វីដែលត្រូវធ្វើជាមួយនឹងការប្ដឹងរាយការណ៍របស់អ្នក។

ខណៈពេលដែលយើងមិនអាចប្រើប្រាស់អំណាចស៊ើបអង្កេតរបស់យើងឲ្យបានទូលំទូលាយច្រើនជាងនេះក្ដីក្នុងអំឡុងពេលនៃការសាកសួរក្នុងជំហានដំបូង យើងអាចនឹង៖

- ស្នើសុំព័ត៌មានបន្ថែមទៀតពីនរណាម្នាក់
- កោះហៅជនម្នាក់មកធ្វើឯកសារ
- ចេញសេចក្ដីជូនដំណឹងអំពីភាពលាក់ការណ៍សម្ងាត់។

## ព័ត៌មានរបស់អ្នកអាចជួយ

មិនថាលទ្ធផលនៃការប្ដឹងរាយការណ៍របស់អ្នកមានលក្ខណៈយ៉ាងណានោះទេ ព័ត៌មានដែលអ្នកផ្ដល់ឲ្យយើងជួយយើងកំណត់អត្តសញ្ញាណទំនោរ និងលំនាំកាន់តែទូលំទូលាយជាងមុន។ IBAC ប្រើប្រាស់ការ វិភាគនេះដើម្បីក្រើនរំលឹកដល់វិស័យសាធារណៈទៅនឹងភាពងាយរងគ្រោះជាសក្ដានុពលនៅក្នុងការអនុវត្តន៍ ឬអង្គការរបស់ពួកគេ។

Level 1, North Tower
459 Collins Street,
Melbourne VIC 3000
GPO Box 24234,
Melbourne, VIC 3001

**ទូរសព្ទ** 1300 735 135
**ទូរសារ** (03) 8635 6444

ខែមករា ឆ្នាំ 2020

IBAC គឺជាភ្នាក់ងារប្រឆាំងអំពើពុករលួយរបស់រដ្ឋវិចតូរីយ៉ាដែលទទួលខុសត្រូវក្នុងការបង្ការ និងបើកបង្ហាញអំពើពុករលួយនៅក្នុងវិស័យសាធារណៈ និងការប្រព្រឹត្តមិនត្រឹមត្រូវរបស់ប៉ូលីស។ យើងបំពេញកិច្ចការនេះដោយ៖

- ស៊ើបអង្កេតអំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវធ្ងន់ធ្ងររបស់ប៉ូលីស
- ជូនដំណឹងដល់វិស័យសាធារណៈ ប៉ូលីស និងសហគមន៍អំពីហានិភ័យ និងផលប៉ះពាល់នៃអំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវរបស់ប៉ូលីស ហើយនិងវិធីទាំងឡាយដែលវាអាចបង្ការកុំឲ្យកើតមាន។

ដើម្បីរាយការណ៍អំពើពុករលួយឥឡូវនេះ សូមចូលមើល **www.ibac.vic.gov.au** ឬហៅទូរសព្ទទៅលេខ **1300 735 135**។

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបកប្រែភាសា សូមទូរស័ព្ទទៅសេវាបកប្រែភាសាសរសេរ និងនិយាយលេខ **13 14 50** ឬចូលមើល **www.ibac.vic.gov.au/general/accessibility/tr**